**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈរដ្ឋមន្ត្រី**

**ក្រសួងបរិស្ថាន**

លេខ:...[illegible]...ប.ស្ត

រាជធានីភ្នំពេញ.ថ្ងៃទី..២១.... ខែ..មិថុនា......ឆ្នាំ២០០៦

# ប្រកាស

## ស្តីពីការរៀបចំសហគមន៍តំបន់ការពារធម្មជាតិ "អូរទុង " ឃុំកុកឡាក់ ស្រុកវើនសៃ ស្ថិតក្នុងតំបន់ឧទ្យានជាតិវីរៈជ័យ ខេត្តរតនៈគីរី

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការបង្កើត និងការកំណត់តំបន់ការពារធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦-៣៦ ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ ៥៧ អនក្រ.បក ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងបរិស្ថាន
- បានឃើញសេចក្តីជូនដំណឹងលេខ ២៩៥ សជណ.កស ចុះថ្ងៃទី ១៦ ខែ មិនា ឆ្នាំ២០០១ របស់ទីស្តីការគណៈរដ្ឋមន្ត្រី
- ផ្អែកតាមតម្រូវការចាំបាច់របស់សហគមន៍មូលដ្ឋានដែលស្ថិតនៅក្នុងតំបន់ឧទ្យានជាតិវីរៈជ័យ ខេត្តរតនៈគីរី។

## សំ រេ ច

ប្រការ១:- រៀបចំសហគមន៍តំបន់ការពារធម្មជាតិដែលស្ថិតនៅក្នុងតំបន់ប្រើប្រាស់ដោយចីរភាព នៃឧទ្យានជាតិវីរៈជ័យ ក្នុងឃុំកុកឡាក់ ស្រុកវើនសៃ ខេត្តរតនៈគីរី មានឈ្មោះថា "**សហគមន៍តំបន់ការពារធម្មជាតិអូរទុង** "។

ប្រការ២:- សហគមន៍តំបន់ការពារធម្មជាតិអូរទុង នៃឧទ្យានជាតិវីរៈជ័យ ស្ថិតក្នុងភូមិសាស្ត្រឃុំកុកឡាក់ ស្រុកវើនសៃ ខេត្តរតនៈគីរី មានផ្ទៃដីប្រាំបួនពាន់ប្រាំបីរយហុកសិបពីរ (**៩៨៦២**) **ហិកតា** ដូចបានកំណត់ក្នុងផែនទី ដែលមានអាប់ស៊ីស និងកូអ័រដោនេព្រំប្រទល់ខាងក្រោម :

| ចំណុច | ឈ្មោះទីតាំង | អាប់ស៊ីស X | អរដោនេ Y | ចំណុច | ឈ្មោះទីតាំង | អាប់ស៊ីស X | អរដោនេ Y |
|---|---|---|---|---|---|---|---|
| A | មាត់អូររ៉កបំបែកពីអូរឡាឡៃ | ៦៩៦៥៣២ | ១៥៧០៣៩៥ | J | ក្បាលអូរប្រាំង | ៧០៣៩៦៩ | ១៥៦៩៩៨៦ |
| B | លើភ្នំហាន់ជ្រី | ៦៩៧៤៨៣ | ១៥៧០៧៣៩ | K | ជើងភ្នំអៀលចេង | ៧០៣៣១៩ | ១៥៧០២៩៧ |
| C | លើភ្នំអូរដាណឹង | ៦៩៨០៨៩ | ១៥៧០៥៥៥ | L | ជើងភ្នំអៀលចេង | ៧០២៤១១ | ១៥៧១២៦៥ |
| D | ចុងអូរដាណឹង | ៦៩៨៤០៥ | ១៥៧០៥៧៩ | M | ជើងភ្នំអៀលចេង | ៧០១៩២៦ | ១៥៧១៦២៥ |
| E | ចុងអូរដាណឹង | ៦៩៨៧៨៥ | ១៥៧១០៨៧ | N | ជើងភ្នំអៀលចេង | ៧០១៣៥៤ | ១៥៧១៦២៥ |
| F | លើភ្នំប្រាំង | ៦៩៩២៩៨ | ១៥៧០៩៨២ | O | ជើងភ្នំឆាងកាឡុក | ៧០១០៩៥ | ១៥៧០៨១០ |
| G | លើភ្នំត្រាវទុក | ៦៩៩៨៨៦ | ១៥៧០៤៥៣ | P | ចុងអូរអង្កុ | ៧០១០៣៤ | ១៥៧០៤២៧ |
| H | លើភ្នំត្រាវទុក | ៧០០៣៥៥ | ១៥៧០៤៨៨ | Q | ជើងភ្នំឆាងកាឡុក | ៧០១០៥៣ | ១៥៧០៤៤៥ |
| I | ក្នុងអូរឆាយជ្រី ចំនុចទឹកធ្លាក់ | ៧០៤២៩៨ | ១៥៦៩៦៦៨ | | | | |

<u>ប្រការ៣:</u>– ការរៀបចំសហគមន៍តំបន់ការពារធម្មជាតិ**អូរខុង** នៃតំបន់ឧទ្យានជាតិវីរៈជ័យ និងការប្រើប្រាស់ធនធានធម្មជាតិក្នុងតំបន់នេះ ត្រូវចុះកិច្ចព្រមព្រៀងជាមួយក្រសួងបរិស្ថាន ហើយសហគមន៍នេះត្រូវមានលក្ខន្តិកៈដោយឡែក ។

<u>ប្រការ៤:</u>– អគ្គនាយកបច្ចេកទេស អគ្គនាយករដ្ឋបាលនិងហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានការពារនិងអភិរក្សធម្មជាតិ ប្រធានមន្ទីរបរិស្ថានខេត្តរតនៈគីរី នាយកឧទ្យានជាតិវីរៈជ័យ អង្គភាពពាក់ព័ន្ធ និងសហគមន៍តំបន់ការពារធម្មជាតិ**អូរខុង** នៃភូមិរ៉ក ភូមិឡាឡៃ ភូមិឡាម៉ើយ ភូមិក្រាក ឃុំកុកឡាក់ ស្រុកវើនសៃ ខេត្តរតនៈគីរី ត្រូវសហការអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*ចំលងជូន:*

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់
- សាលាខេត្តរតនៈគីរី
- គំរោងគ្រប់គ្រងជីវៈចម្រុះ និងឧទ្យានជាតិវីរៈជ័យ
- ដូចប្រការ ៤" ដើម្បីអនុវត្ត"
- ឯកសារ, កាលប្បវត្តិ

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន

ម៉ុក_ម៉ារ៉េត